# បញ្ជីសំណួរ

## សម្រាប់តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

| ផ្នែកដែលត្រូវស្វែងយល់ | បញ្ជីសំណួរ ឆ្លើយតបនឹងប្រធានបទ |
|---|---|
| *គោលបំណងទី១. កំណត់រកចន្ថថ្មីនៃអំពើជួញដូរមនុស្ស និងវិធីសាស្ត្រ (modus operandi) ដែលជនល្មើសជួញដូរកំពុងប្រើប្រាស់ក្នុងបរិបទកូវី១៩ ក្នុងគោលដៅជួញដូរពលរដ្ឋកម្ពុជាជាពិសេសស្ត្រី និងកុមារ* | |
| • **ផលប៉ះពាល់នៃ ការរីករាលនៃជំងឺកូវីដ១៩ លើរូបភាពចរន្ត នៃអំពើជួញដូរមនុស្ស** | 1. តាមការសង្កេតឃើញរបស់អ្នក តើអ្វីដែលជារូបភាពថ្មីនៃអំពើជួញដូរមនុស្សចាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ឆ្នាំ២០២២នេះ?<br>2. តើទំរង់/ករណីនៃអំពើជួញដូរមនុស្សមួយណា (ជួញដូរផ្លូវភេទ ការរំលោភបំពានផ្លូវភេទប្រព័ន្ធ Online កេងប្រវ័ញ្ចកម្លាំងពលកម្ម ជាពិសេសក្នុងចំណោមស្ត្រីកម្មករការងារផ្ទះ ការពពោះជំនួស អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទះ..) ដែលអ្នកបានជួបប្រទះច្រើនជាងគេក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩?<br>3. តើអ្នកដឹងទេថា តើជនល្មើសជួញដូរមនុស្ស ប្រើប្រាស់វិធីសាស្ត្របែបណាដើម្បីទំនាក់ទំនងជាមួយជនរងគ្រោះ?<br>4. តើជនល្មើសជួញដូរមនុស្សប្រើប្រាស់វិធីសាស្ត្រអ្វី ឬដោយរបៀបណាដើម្បីអាចឆ្លងទៅប្រទេសគោលដៅបាន ជាពិសេសក្នុងអំឡុងពេលបិទខ្ទប់ និងបិទព្រំដែន?<br>5. តើក្រុមមនុស្សមួយណា ដែលរងគ្រោះច្រើនជាងគេ (ស្ត្រី កុមារ ជនទេសន្តរប្រវេសន៍ អ្នកស្រឡាញ់ភេទដូចគ្នា ក្រុមមនុស្សវ័យចំណាស់ ជនជាតិដើមភាគតិច ឬក្រុមសាសនាភាគតិច ឬក្រុមផ្សេងទៀត) |
| *គោលបំណងទី២. ចងក្រងនូវឧត្តមានុវត្តន៍ បញ្ហាប្រឈម និងដំណោះស្រាយ ឆ្លើយតបរបស់ប្រតិបត្តិករប្រយុទ្ធប្រឆាំងជួញដូរមនុស្សក្នុងបរិបទកូវីដ១៩នៅកម្ពុជា* | |
| • **ផលប៉ះពាល់នៃការរីករាលនៃជំងឺកូវីដ១៩ លើការផ្តល់សេវាឆ្លើយតបនឹងអំពើ** | 1. តើអ្វីដែលជាបញ្ហាប្រឈមរបស់អ្នកក្នុងការអនុវត្តការងារប្រចាំថ្ងៃ ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ ដូចជាក្នុងដំណាក់កាលៈ<br>• ការកំណត់សញ្ញាណជនរងគ្រោះ<br>• ការផ្តល់កិច្ចការពារ និងផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះ |

| | |
|---|---|
| ជួញដូរមនុស្ស | • ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ<br>• ការស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ នៅក្នុងនីតិវិធីតុលាការ (ស៊ើបអង្កេត, ការកាត់ទោស និងសាវនាការ)<br>2. តើ ស្ថាប័នរបស់អ្នកប្រើប្រាស់វិធីសាស្ត្រអ្វី ឬយន្តការអ្វី ដើម្បីអាចធានាបាននូវដំណើរការនៃការ ផ្តល់សេវាក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩?<br>3. តើអ្នកអាចដឹងទេថា តើវិធីសាស្ត្រ/អភិក្រមអ្វី ដែលមានប្រសិទ្ធភាពជាងគេ ដែលអាចធានាបាននូវ ដំណើរការនៃការផ្តល់សេវាក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩? តើ វិធីសាស្ត្រ/អភិក្រមនេះ គួរតែនៅបន្ត នៅពេលមានវិបត្តិនានានៅពេលអនាគតដែរឬទេ?<br>4. តើអ្នក ឬដៃគូពាក់ព័ន្ធផ្សេងទៀត ត្រូវការធនធានឬវិធីសាស្ត្រអ្វី ដើម្បីអាចធាបាននូវនិរន្តរភាពដំណើរការនៃការផ្តល់សេវា ទោះបីជាមានបញ្ហាប្រឈម ឬឧបសគ្គដូចដែលបានរៀបរាប់ខាងលើ?<br>5. តើប្រតិបត្តិករទាំងអស់ ត្រូវធ្វើដូចម្តេចដើម្បីអាចធានាបានថា ស្ត្រីនិងក្រុមងាយរងគ្រោះផ្សេងទៀតអាចទទួលបានសេវានិងកិច្ចការពារ ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩?<br>6. តើមានអ្វីសំខាន់ផ្សេងទៀតឬទេ ដែលអ្នកចង់ប្រាប់អ្នកសម្ភាសន៍បានដឹងពីផលប៉ះពាល់នៃជំងឺកូវីដ១៩ (ឧទាហរណ៍ ការរំលោភបំពានលើកុមារ, អំពើហិង្សាទាក់ទងនឹងយេនឌ័រ, បន្ទុកការងារផ្ទះសម្រាប់ស្ត្រីកើនឡើង, បណ្តាញមិនផ្លូវការដើម្បីគាំទ្រស្ត្រី, បញ្ហាទាក់ទងសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ដូចជា មានផ្ទៃពោះដោយចៃដន្យ និងបញ្ហាក្នុងការទទួលបានសេវាសុខភាពបន្តពូជ ។ល។ |
| • **វិធីសាស្ត្រដែលបានប្រើប្រាស់ដែលអាចដោះស្រាយបញ្ហាប្រឈមដែលកើតមាន** | 1. តើវិធីសាស្ត្រទំនាក់ទំនងអ្វីខ្លះ (ចែកសម្ភារៈផ្សព្វផ្សាយ, ផ្សព្វផ្សាយតាមបណ្តាញសង្គម, ប្រើប្រាស់ hotline ជាដើម) ដែលអាចផ្តល់ព័ត៌មានច្បាស់លាស់ និងគាំទ្រដល់ជនរងគ្រោះ និងជនងាយរងគ្រោះនៅពេលធ្វើចត្តាឡីស័ក?<br>2. តើការអនុវត្តវិធានការសុវត្ថិភាព ដោយប្រើប្រាស់សម្ភារៈ PPE ដើម្បីផ្តល់សេវាជួយជនរងគ្រោះ ជាជម្រើសដែរឬទេ? ហើយវាមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?<br>3. តើមានតម្រូវការ ផ្នែកកិច្ចគាំពារសង្គម (សំខាន់ជាងគេគឺនៅតាមផ្ទះ និងកម្រិតសហគមន៍) អ្វីខ្លះ ដើម្បីកាត់បន្ថយហានិភ័យនិងភាពងាយរងគ្រោះនឹងអំពើជួញដូរមនុស្ស- តើគួរតម្រូវការ កិច្ចគាំពារសង្គម គួរមានភាពខុសគ្នារវាងស្ត្រីនិងបុរសដែរទេ? |

<table>
<tr><td></td><td>4. តើអ្នកដឹងទេថា កន្លងមកមានបណ្ដាញដើម្បីគាំទ្រជនងាយរងគ្រោះជាស្ត្រីដែរឬទេ? បើមាន តើបណ្ដាញទាំងនោះអាចជួយបានអ្វីខ្លះ?<br>5. តើវិធានការបែបណា ដែលគួរតែបញ្ចូលទៅក្នុង កិច្ចអន្តរាគមន៍/គម្រោងកម្មវិធី ដើម្បីត្រៀមឆ្លើយតបនឹងអំពើជួញដូរមនុស្ស ក្នុងអំឡុងពេលមានការរីករាលដាលនៃជំងឺឆ្លង នាពេលខាងមុខ?</td></tr>
<tr><td colspan="2">គោលបំណងទី៣៖ ស្វែងយល់ពីការអនុវត្តក្របខណ្ឌនៃការគ្រប់គ្រងគ្រោះមហន្តរាយ (Disaster Management Cycle) ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងអំឡុងនិងក្រោយពេលមានគ្រោះមហន្តរាយ ឬវិបត្តិដោយសារជំងឺឆ្លងផ្សេងៗនាពេលអនាគត។</td></tr>
<tr><td>• ស្វែងយល់ពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងផលប៉ះពាល់នៃគ្រោះធម្មជាតិ រួមទាំងការរីករាលដាលនៃជំងឺកូវីដ១៩ និងឫសគល់នៃអំពើជួញដូរមនុស្ស</td><td>1. តើកន្លងមកអ្នក ធ្លាប់ចូលរួមសិក្ខាសាលា ឬទទួលបាននូវវគ្គបណ្ដុះបណ្ដាល ដែលអាចជួយអ្នកអនុវត្តសកម្មភាពទប់ស្កាត់ ការសម្គាល់អំពើជួញដូរមនុស្ស និងការបញ្ជូនជនរងគ្រោះទៅរកជំនួយ ក្នុងអំឡុងពេលមានគ្រោះមហន្តរាយ ដែរឬទេ?<br>2. តើអ្នកគិតថា ចាំបាច់ឬទេ ក្នុងការទទួលបានវគ្គបណ្ដុះបណ្ដាលលើប្រធានបទដូចខាងលើ?<br>3. តើអ្នកគិតថា ផលប៉ះពាល់អ្វីខ្លះ បណ្ដាលមកពីគ្រោះធម្មជាតិ (ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត ជំងឺឆ្លង...) លើផ្នែកសង្គម សេដ្ឋកិច្ច និងសន្តិសុខ?<br>4. តើអ្នកយល់ឃើញថា កត្តាជំរុញ និងផលប៉ះពាល់នៃគ្រោះមហន្តរាយ និងផលប៉ះពាល់ដែលបណ្ដាលមកពីជំងឺកូវីដ១៩ មានទំនាក់ទំនងអាចបង្កើន ភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែរឬទេ? តើផលប៉ះពាល់នោះខុសគ្នាឬទេ រវាងបុរស និងស្ត្រី?<br>5. តើអ្នកគិតថា តើគួរមានសកម្មភាព ឬកិច្ចអន្តរាគមន៍អ្វីខ្លះ ដើម្បីអាចទប់ស្កាត់ ឬកំណត់សម្គាល់អំពើជួញដូរមនុស្សនៅក្នុងអំឡុងពេលអ្នកផ្ដល់ជំនួយបន្ទាន់ ពេលមានគ្រោះមហន្តរាយកើតឡើង? តើអ្នកមានតម្រូវការអ្វីខ្លះ (ធនធាន កិច្ចសហការ ឬក្រុមការងារ)ដើម្បីអាចអនុវត្តន៍សកម្មភាពដែលអ្នកបានលើកឡើង និងអាចធានានិរន្តរភាពនៃសកម្មភាពនេះបាន?<br>6. តាមដែលអ្នកដឹង តើកន្លងមកធ្លាប់មានការធ្វើការប៉ាន់ប្រមាណពាក់ព័ន្ធនឹងហានិភ័យនៃអំពើជួញដូរមនុស្ស ចំពោះសហគមន៍ដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែរទេ? តើមានការយល់ដឹងពីផលប៉ះពាល់ផ្សេងៗគ្នា រវាងបុរស និងស្ត្រីដែរទេ?</td></tr>
</table>

| | |
|---|---|
| | 7. តើអ្នកគិតថា ការធ្វើការប៉ាន់ប្រមាណពាក់ព័ន្ធនឹងហានិភ័យនៃអំពើជួញដូរមនុស្ស ចំពោះសហគមន៍ដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ មានសារៈសំខាន់ដែរឬទេ? បើមាន តើធនធាន ឬតម្រូវការអ្វីខ្លះ ដែលចាំបាច់ ដើម្បីធ្វើការប៉ាន់ប្រមាណនេះ? ហើយតើព័ត៌មានអ្វី ដែលអ្នកចង់បាន នៅក្នុងការធ្វើការប៉ាន់ប្រមាណនេះ?<br>8. តើធនធាន តម្រូវការ និងកិច្ចអន្តរាគមន៍អ្វីខ្លះឆ្លើយតបនឹងតម្រូវការយេនឌ័រ ដែលអាចមានប្រសិទ្ធភាពដើម្បីទប់ស្កាត់ភាពងាយរងគ្រោះទៅនឹងអំពើជួញដូរមនុស្ស ក្នុងចំណោមសហគមន៍ដែលរងផលប៉ះពាល់?<br>9. តើធ្វើដូចម្តេចដើម្បីអាចធានាបាននូវនិរន្តរភាពនិងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំង អំពើ ជួញដូរមនុស្ស ទោះក្នុងអំឡុងពេលគ្រោះមហន្តរាយ ការរាតត្បាតនៃជំងឺឆ្លង ឬវិបត្តិផ្សេងៗ?<br>10. បង្ហាញពី គម្រូ ស្តីពី វដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានបញ្ចូលសកម្មភាព/កិច្ចអន្តរាគមន៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ តើអ្នកគិតថា សកម្មភាព/កិច្ចអន្តរាគមន៍ណាដែលចាំបាច់ និងអាចអនុវត្តបាន ស្របនឹងបរិបទកម្ពុជា?<br>11. តើអ្នកគិតថា គួរតែមាន កិច្ចអន្តរាគមន៍ឬយន្តការជាយុទ្ធសាស្រ្ត (ឧទាហរណ៍ បញ្ចូលសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងអំឡុងពេលមានគ្រោះមហន្តរាយទៅក្នុងផែនការយុទ្ធសាស្រ្តជាតិ ភ្ជាប់ទំនាក់ទំនងរវាងក្រុមការងារ គ.ជ.ប.ជ និងក្រុមការងារនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ) ដែរឬទេ ដើម្បីធានាបាននូវប្រសិទ្ធភាព កិច្ចខិតខំប្រឹងប្រែង និងដំណើរការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទោះបីជាក្នុងអំឡុងពេលគ្រោះមហន្តរាយ ការរាតត្បាតនៃជំងឺឆ្លង ឬវិបត្តិផ្សេងៗ?<br>12. តើត្រូវការធនធាន ឬបុរេលក្ខខណ្ឌ បន្ថែមអ្វីខ្លះទៀតដែរឬទេ ដើម្បីអនុវត្តសកម្មភាពទាំងនេះបានកាន់តែមានប្រសិទ្ធភាពខ្ពស់ ដោយឆ្លើយតបនឹងយេនឌ័រ និងបរិយាប័ន្ន? |